ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាម
បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ របស់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់បណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា គ.ជ.អ.ប នឹងរៀបចំសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ របស់ គ.ជ.អ.ប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ពេជ្រ ប៊ុន ធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ក្នុងពិធីបើក នាវេលាម៉ោង ៨.៣០ ព្រឹក ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ និងឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប **ក្នុងពិធីបិទ វេលាម៉ោង** ១០.០០ ព្រឹក ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣។ សិក្ខាសាលានេះនឹងមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ សរុបជាង ៤០០ នាក់។

សិក្ខាសាលានេះមានគោលបំណងពិភាក្សាអំពីការវិភាជន៍ថវិកាសម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ របស់ គ.ជ.អ.ប និងអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងឆ្នាំ២០១៣ ព្រមទាំងលទ្ធផលរំពឹងទុក និងផែនការសកម្មភាពគ្រោងសម្រាប់អនុវត្តក្នុងឆ្នាំ២០១៤។

**ពេលវេលា:** ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ ចាប់ពីម៉ោង ៧:៣០ ព្រឹក រហូតដល់ម៉ោង ៥:០០ ល្ងាច
ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ចាប់ពីម៉ោង ៧:៣០ ព្រឹក រហូតដល់ម៉ោង ១១.៣០ ព្រឹក

**ទីកន្លែង:** នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ (អគារ S) អាសយដ្ឋាន: មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីដែលជាអ្នកសារព័ត៌មានទាំងអស់អញ្ជើញចូលរួមយកព័ត៌មានតាមកាលបរិច្ឆេទ និងពេលវេលាខាងលើកុំបីខាន។

*ព័ត៌មានបន្ថែម សូមទំនាក់ទំនងលោក ជេដ្ឋ គីមជុង ប្រធានការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន នៃលេខាធិការដ្ឋាន គ.ជ.អ.ប តាមរយៈលេខទូរស័ព្ទ ០១២ ៧៥៨ ៥២០ អ៊ីម៉ែល: kimchung@ncdd.gov.kh គេហទំព័រ: www.ncdd.gov.kh ។*